ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៨.....អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការជាតិកិច្ចសម្រួលពាណិជ្ជកម្ម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារ នៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០១ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារ សម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មទៅក្នុងឧបសម្ព័ន្ធ ១ក នៃកិច្ចព្រមព្រៀងម៉ារ៉ាកេស
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



Media from www.moj.gov.kh resource from www.ocm.gov.kh

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត "**គណៈកម្មាធិការជាតិកិច្ចសម្រួលពាណិជ្ជកម្ម**" ហៅកាត់ថា **គ.ជ.ស.ព** ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួល និងតាមដានការអនុវត្តបញ្ញត្តិនានាក្នុងកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក។

**គ.ជ.ស.ព** ត្រូវមានលេខាធិការដ្ឋាននៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់បម្រើការងាររបស់ខ្លួន។ ការរៀបចំ និងប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ជ.ស.ព** ត្រូវកំណត់ដោយប្រធាន **គ.ជ.ស.ព**។

## ជំពូកទី២
## សមាសភាពនិងរចនាសម្ព័ន្ធរបស់ គ.ជ.ស.ព

**មាត្រា២.-**

**គ.ជ.ស.ព** មានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. | អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥. | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦. | តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៧. | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨. | តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៩. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០. | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១១. | តំណាងរដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១២. | តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៣. | តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |

**មាត្រា៣.-**

**គ.ជ.ស.ព** អាចចេញសេចក្តីសម្រេចកែសម្រួលសមាសភាព ឬបង្កើតក្រុមការងារបច្ចេកទេសតាមការចាំបាច់ ដើម្បីសម្របសម្រួល និងតាមដានការអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ គ.ជ.ស.ព

**មាត្រា៤.-**

**គ.ជ.ស.ព** មានតួនាទីនិងភារកិច្ច សម្របសម្រួលនិងតាមដានការអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក ដូចខាងក្រោម÷

- សម្របសម្រួល កសាងសេចក្តីព្រាងបទប្បញ្ញត្តិ និងនីតិវិធីចាំបាច់នានា តាមការស្នើសុំរបស់ក្រសួងស្ថាប័ន និងផ្នែកឯកជន ដើម្បីគាំទ្រការអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម
- ផ្តល់យន្តការប្រឹក្សាយោបល់ពាក់ព័ន្ធនឹងការអនុវត្តបទប្បញ្ញត្តិនិងនីតិវិធី រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីឱ្យការអនុវត្តបទប្បញ្ញត្តិនិងនីតិវិធីពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្មមានភាពសាមញ្ញ មានស្តង់ដារ និងងាយអនុវត្ត
- ទំនាក់ទំនងសហការជាមួយអង្គការអន្តរជាតិនិងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដើម្បីកៀរគរនិងសម្របសម្រួលធនធាន ដើម្បីអនុវត្តកិច្ចសម្រួលពាណិជ្ជកម្ម
- បង្កើតគេហទំព័រ ដើម្បីចែករំលែកព័ត៌មានស្តីពីបទប្បញ្ញត្តិនិងនីតិវិធីដល់សាធារណជន
- លើកគម្រោងថវិកាចំណាយសម្រាប់កិច្ចដំណើរការ គ.ជ.ស.ព
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.ស.ព

**មាត្រា៥.-**

គ.ជ.ស.ព ត្រូវរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ និងកិច្ចប្រជុំផ្សេងទៀតតាមការតម្រូវ
- សមាជិកនៃ គ.ជ.ស.ព ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន
- ប្រធាន គ.ជ.ស.ព ត្រូវដឹកនាំអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវដឹកនាំអង្គប្រជុំជំនួស តាមការប្រគល់ភារកិច្ចពីប្រធាន
- ប្រធាន គ.ជ.ស.ព អាចអញ្ជើញមន្ត្រីជំនាញ ឬ តំណាងក្រសួង-ស្ថាប័នផ្សេងទៀត ដែលមិនមែនជាសមាជិកនៃ គ.ជ.ស.ព ចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា៦.-**

គ.ជ.ស.ព អាចមានទីប្រឹក្សា និង/ឬ ជំនាញការជាតិនិងអន្តរជាតិតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក។

តួនាទី ភារកិច្ច ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗសម្រាប់ទីប្រឹក្សា និង/ឬ ជំនាញការជាតិនិងអន្តរជាតិ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ស.ព។

## ជំពូកទី៥
## ប្រភពធនធាននិងថវិកា

**មាត្រា៧.-**

ការចំណាយសម្រាប់ដំណើរការ គ.ជ.ស.ព ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ ថវិកាស្របច្បាប់ ដែលបានមកពីប្រភពផ្សេងៗទៀត។

គ.ជ.ស.ព មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីជាធរមាននូវមូលនិធិ ដែលបានមកពីប្រភពផ្សេងៗសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៤ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច លោកជំទាវ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Media from www.moj.gov.kh resource from www.ocm.gov.kh